# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៧២០. អនក្រ.បក

## អនុក្រឹត្យ
## ស្ដីពី
## ការបង្កើតក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ"

## រាជរដ្ឋាភិបាល

បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០១៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៥១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្ដីពីការអនុវត្តព្រះរាជក្រមលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញកិច្ចព្រមព្រៀងបង្កើតក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩
- បានឃើញវិសោធនកម្មលើកិច្ចព្រមព្រៀងបង្កើតក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១១
- តាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

## ជំពូកទី១
## បទបញ្ញត្តិទូទៅ

**មាត្រា ១.**

ត្រូវបានបង្កើតក្រុមហ៊ុនអាកាសចរជាតិមួយ ដែលមានឈ្មោះថា កម្ពុជា អង្គរ អ៊ែរ (Cambodia Angkor Air Co. Ltd.) សរសេរកាត់ជាភាសាខ្មែរ "ក.អ.អ" និងសរសេរកាត់ជាភាសាអង់គ្លេស (CAAir) ។

**មាត្រា ២.**

ក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវបានបង្កើតឡើងដែលមានទឹកប្រាក់វិនិយោគសរុបចំនួន ១០០ (មួយរយ)លាន ដុល្លាអាមេរិក ដែលមានទំរង់ជាក្រុមហ៊ុនចម្រុះរដ្ឋ និងឯកជន ដែលភាគីកម្ពុជាមានភាគហ៊ុនចំនួន ៥១ (ហាសិបមួយ)ភាគរយ និងភាគីក្រុមហ៊ុនអាកាសចរជាតិវៀតណាមមានភាគហ៊ុនចំនួន ៤៩ (សែសិបប្រាំបួន)ភាគរយ ។ ចំណែកឯភាគហ៊ុនរបស់ភាគីកម្ពុជា រាជរដ្ឋាភិបាលកម្ពុជា មានភាគហ៊ុនចំនួន ២៥ (ម្ភៃប្រាំ)ភាគរយ និងក្រុមហ៊ុនវិនិយោគកម្ពុជាមានភាគហ៊ុនចំនួន ២៦ (ម្ភៃប្រាំមួយ)ភាគរយ ។

**មាត្រា ៣.**

ក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវបានគ្រប់គ្រងដោយបទបញ្ញត្តិ ដូចតទៅ÷

- ព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- អនុក្រឹត្យលេខ ៤១ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការអនុវត្តព្រះរាជក្រមស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- កិច្ចព្រមព្រៀងបង្កើតក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩
- វិសោធនកម្មលើកិច្ចព្រមព្រៀងបង្កើតក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១១
- អនុក្រឹត្យស្តីពីការបង្កើតក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ"
- លក្ខន្តិកៈក្រុមហ៊ុន

**មាត្រា ៤.**

ការបង្កើតក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" មានគោលដៅ÷

- ធ្វើប្រតិបត្តិការអាជីវកម្មដឹកជញ្ជូនតាមផ្លូវអាកាស ទាំងក្នុងស្រុក និងក្រៅស្រុក
- ធ្វើប្រតិបត្តិការអាជីវកម្ម ដែលពាក់ព័ន្ធនឹងវិស័យដឹកជញ្ជូនផ្លូវអាកាសស្របតាមច្បាប់ នៃព្រះរាជាណាចក្រកម្ពុជា និង/ឬវិស័យផ្សេងទៀត ទៅតាមកិច្ចព្រមព្រៀងជាបន្តបន្ទាប់
- ផ្តល់សេវាកម្មគាំទ្រដល់ឧស្សាហកម្មទេសចរណ៍នៅកម្ពុជា ។

**មាត្រា ៥.**

ក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវទទួលបានការលើកទឹកចិត្តផ្នែកពន្ធដូចតទៅ÷

- នៅពេលក្រុមហ៊ុនមិនទាន់បានប្រមូលទុនវិនិយោគមកវិញពីការធ្វើអាជីវកម្ម ពន្ធអាករទាំងអស់ជាបន្ទុករបស់រដ្ឋ លើកលែងតែពន្ធលើប្រាក់ចំណេញ និងពន្ធកាត់ទុក
- ក្រុមហ៊ុនត្រូវបង់ពន្ធលើប្រាក់ចំណេញតាមអត្រា ០៩ (ប្រាំបួន)ភាគរយ ក្រោយពីប្រតិបត្តិការអាជីវកម្មបានរយៈពេល ០៨ (ប្រាំបី)ឆ្នាំ
- ក្រុមហ៊ុនត្រូវបង់ពន្ធកាត់ទុកតាមអត្រា ០២ (ពីរ)ភាគរយ រហូតដល់ពេលដែលក្រុមហ៊ុនប្រមូលបានទុនវិនិយោគមកវិញ
- បន្ទាប់ពីបានប្រមូលទុនវិនិយោគមកវិញ ភាគីក្រោមកិច្ចព្រមព្រៀង នឹងត្រូវជួបចរចាគ្នា ដើម្បីពិនិត្យពីលទ្ធភាពក្នុងការផ្តល់ការលើកទឹកចិត្តផ្នែកពន្ធដល់ក្រុមហ៊ុន ។

**មាត្រា ៦.**

ក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវទទួលបានការលើកទឹកចិត្តផ្សេងទៀត ដូចមានចែងក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើតក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៩ រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនអាកាសចរជាតិវៀតណាម ។

## ជំពូកទី២
## ការដឹកនាំនិងការគ្រប់គ្រង

**មាត្រា ៧.**

ក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេសរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រោមអាណាព្យាបាលហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ៨.**

ក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាលចំនួន ១១រូប ដែលមានសិទ្ធិពេញលេញ ក្នុងការបំពេញការងារក្នុងក្របខណ្ឌនៃបទបញ្ញត្តិនៃអនុក្រឹត្យនេះ និងលក្ខន្តិកៈរបស់ខ្លួន ។

ក្រុមប្រឹក្សាភិបាលមានសមាសភាពដូចខាងក្រោម÷

| | | |
|---|---|---|
| - តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | ១ រូប | ប្រធាន |
| - តំណាងរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | ១ រូប | សមាជិក |
| - តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១ រូប | សមាជិក |
| - តំណាងក្រុមហ៊ុនអាកាសចរជាតិវៀតណាម | ៥ រូប | សមាជិក |
| - តំណាងក្រុមហ៊ុនវិនិយោគកម្ពុជា | ៣ រូប | សមាជិក |

សមាជិកក្រុមប្រឹក្សាភិបាល ដែលជាសមាសភាពមកពីស្ថាប័នរដ្ឋ ត្រូវតែងតាំងដោយអនុក្រឹត្យសម្រាប់អាណត្តិ ០៣ (បី)ឆ្នាំ ។ អាណត្តិនេះអាចបញ្ចប់ ឬអាចបន្តទៀតបានដោយអនុក្រឹត្យ តាមសំណើរបស់ក្រសួង ស្ថាប័ន ឬអង្គភាពដែលខ្លួនតំណាងឲ្យ ។

**មាត្រា ៩.**

ក្រុមប្រឹក្សាភិបាលមានសិទ្ធិពេញលេញតាមអាណត្តិ និងសិទ្ធិដែលបានទទួលពីម្ចាស់ភាគហ៊ុន ដើម្បីសម្រេចក្នុងនាមក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ក្នុងការរៀបចំលិខិតស្នាម ឯកសារផ្សេងៗទាក់ទងទៅនិងកម្មវត្ថុអាជីវកម្មរបស់ក្រុមហ៊ុន ស្របតាមច្បាប់ជាធរមាន ។

ក្រុមប្រឹក្សាភិបាលមានតួនាទីដូចខាងក្រោម-

- សម្រេចលើគម្រោងផែនការរបស់ក្រុមហ៊ុន
- វាយតម្លៃរៀងរាល់ពេលនូវលទ្ធផលដែលបានគ្រោងទុក ព្រមទាំងចាត់វិធានការដើម្បីកែសម្រួលឲ្យបានស្របតាមសភាពការណ៍
- សម្រេចលើរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ និងរបាយការណ៍សកម្មភាពរបស់ក្រុមហ៊ុន
- សម្រេចលើសំណើសមស្របរបស់អគ្គនាយក ទាក់ទងនឹងអភិបាលកិច្ច រចនាសម្ព័ន្ធ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ព្រមទាំងលក្ខន្តិកៈ និងកាំប្រាក់បៀវត្ស ប្រាក់រង្វាន់ និងប្រាក់ឧបត្ថមផ្សេងៗសម្រាប់បុគ្គលិក ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិទាំងឡាយជាធរមាន ។
- សម្រេចលើកិច្ចសន្យា និងអនុសញ្ញា ដែលក្រុមហ៊ុនជាភាគីហត្ថលេខីស្របតាមល័ក្ខខណ្ឌ និងបែបបទដូចមានចែងក្នុងបទបញ្ជាជាធរមាន
- បង្កើត បើក ឬបិទការិយាល័យ និងទីស្នាក់ការគ្រប់កន្លែងរបស់ក្រុមហ៊ុន តាមការវិនិច្ឆ័យរបស់ខ្លួន
- សម្រេចលើការប្រើប្រាស់ប្រាក់ចំណេញរបស់ក្រុមហ៊ុន ស្របតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន។

**មាត្រា ១០.**

ក្រុមប្រឹក្សាភិបាល មានប្រធានក្រុមប្រឹក្សាភិបាលចំនួន ០១ (មួយ)រូប ដែលចាត់តាំងដោយរាជរដ្ឋាភិបាលកម្ពុជា ចេញពីសមាសភាពក្រុមប្រឹក្សាភិបាលរបស់ខ្លួន ។ ប្រធានក្រុមប្រឹក្សាភិបាល មានតួនាទីដូចខាងក្រោម÷

- ជាប្រធានកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល
- ទំនាក់ទំនងឆ្លើយឆ្លងជាមួយម្ចាស់ភាគហ៊ុន រាជរដ្ឋាភិបាលកម្ពុជា បណ្តារដ្ឋាភិបាលបរទេស និងទីភ្នាក់ងារនានាបើចាំបាច់ ។
- គ្រប់គ្រងនិងតាមដានកិច្ចការងាររបស់ក្រុមប្រឹក្សាភិបាល
- កំណត់របៀបវារៈកិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ដោយមានកិច្ចសហការណ៍ពីអគ្គនាយកក្រុមហ៊ុន
- តាមដានកិច្ចការងារដែលបានសម្រេចដោយក្រុមប្រឹក្សាភិបាល អោយអគ្គនាយកក្រុមហ៊ុនជាអ្នកអនុវត្តន៍
- សម្របសម្រួលជាមួយសមាជិកក្រុមប្រឹក្សាភិបាល ដើម្បីទទួលបានព័ត៌មានគ្រប់គ្រាន់ អំពីដំណើរការអាជីវកម្មរបស់ក្រុមហ៊ុន
- ជាទីប្រឹក្សាចំពោះសមាជិកក្រុមប្រឹក្សាភិបាល
- ជាអ្នកតំណាងក្រុមប្រឹក្សាភិបាល ។

**មាត្រា ១១.**

ក្រុមប្រឹក្សាភិបាលត្រូវធ្វើការប្រជុំរៀងរាល់ ០៣ (បី)ខែម្តងយ៉ាងតិច ។ កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល អាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពី ០៦ (ប្រាំមួយ)នាក់ ។ ក្នុងករណីមិនមានកូរ៉ុម ការប្រជុំត្រូវលើកទៅ ០៥ (ប្រាំ)ថ្ងៃក្រោយ ដើម្បីពិភាក្សាលើរបៀបវារៈដដែល ។ កិច្ចប្រជុំលើកក្រោយនេះ ត្រូវមានសមាជិកលើសពី ០៦ (ប្រាំមួយ)នាក់ ។ ក្នុងករណីដែលសមាជិកចូលរួមមានចំនួនមិនគ្រប់កូរ៉ុម ចំនួន ០៣ (បី)ដងជាប់ៗគ្នា ប្រធានក្រុមប្រឹក្សាភិបាល ត្រូវលើកយកបញ្ហាខាងលើ ទៅដាក់ជារបៀបវារៈក្នុងកិច្ចប្រជុំម្ចាស់ភាគហុនដើម្បីដោះស្រាយ ។ របៀបវីរៈនៃការប្រជុំ ព្រមទាំងឯកសារទាក់ទិនទាំងឡាយត្រូវផ្ញើរជូនសមាជិកក្រុមប្រឹក្សាភិបាលគ្រប់រូបនិងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានយ៉ាងតិច ១០ (ដប់)ថ្ងៃ មុនពេលបើកអង្គប្រជុំ ។

**មាត្រា ១២.**

កំណត់ហេតុប្រជុំរបស់ក្រុមប្រឹក្សាភិបាល ត្រូវរៀបចំក្នុងរយៈពេល ១០ (ដប់)ថ្ងៃ ក្រោយការប្រជុំ ហើយត្រូវបញ្ជូនទៅក្រសួង ស្ថាប័ន ឬអង្គភាពអាណាព្យាបាល សមាជិកក្រុមប្រឹក្សាភិបាលម្នាក់ៗ និងមន្ត្រីត្រួតពិនិត្យរដ្ឋឲ្យបានមុនការប្រជុំក្រុមប្រឹក្សាភិបាលលើកក្រោយ ។ កំណត់ហេតុប្រជុំនេះ ត្រូវចុះហត្ថលេខាដោយប្រធានអង្គប្រជុំ ។

**មាត្រា ១៣.**

ក្រុមប្រឹក្សាភិបាលណែនាំ និងប្រគល់ឲ្យអគ្គនាយកនូវអំណាចចាំបាច់ទាំងឡាយ សម្រាប់ចាត់ចែងការងារប្រចាំថ្ងៃដើម្បីមានលទ្ធភាពគ្រប់គ្រាន់ ក្នុងការដឹកនាំក្រុមហ៊ុនស្របតាមច្បាប់ ។

អគ្គនាយកមានភារកិច្ចដូចតទៅ÷

- រៀបចំឯកសារទាំងឡាយ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលពិនិត្យ និងសម្រេច និងចាត់ចែងអនុវត្តរាល់សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល តាមដំណាក់កាលនីមួយៗ និងត្រូវរាយការណ៍ជូនក្រុមប្រឹក្សាភិបាលអំពីសកម្មភាពរបស់ក្រុមហ៊ុន
- ដឹកនាំក្រុមហ៊ុន លើផ្នែករដ្ឋបាល បច្ចេកទេសអាជីវកម្ម សេវាកម្ម និងហិរញ្ញវត្ថុ
- ជ្រើសរើស តែងតាំង ដកហូតតំណែង ឬបញ្ឈប់ការងារ និងគ្រប់គ្រងបណ្តាភ្នាក់ងារ ឬមន្ត្រីគ្រប់រូបដែលជានិយោជិករបស់ក្រុមហ៊ុន ដោយគោរពតាមលក្ខន្តិកៈរបស់ក្រុមហ៊ុន លក្ខន្តិកៈបុគ្គលិក ឬច្បាប់និងបទប្បញ្ញត្តិជាធរមាន និងតាមការសម្រេចរបស់ក្រុមប្រឹក្សាភិបាល
- មានសិទ្ធិផ្ទេរអំណាចមួយភាគ ឬទាំងអស់ រួមទាំងផ្ទេរសិទ្ធិចុះហត្ថលេខាទៅមន្ត្រីនៅក្រោមឱវាទស្របតាមលក្ខខណ្ឌ ដែលបានកំណត់ដោយក្រុមប្រឹក្សាភិបាល
- តំណាងឲ្យក្រុមហ៊ុន និងទទួលខុសត្រូវចំពោះមុខតុលាការគ្រប់ជាន់ថ្នាក់ ក្នុងករណីមានការចោទប្រកាន់តវ៉ា ការពារក្តីឲ្យក្រុមហ៊ុន និងប្តឹងជំទាស់ផ្សេងៗ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនប្រគល់ជូន ។

**មាត្រា ១៤.**

ក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវដឹកនាំគ្រប់គ្រងដោយអគ្គនាយក និងអគ្គនាយករង មួយចំនួនតាមការចាំបាច់ ។ អគ្គនាយកត្រូវតែងតាំងដោយក្រុមប្រឹក្សាភិបាល តាមសំណើរបស់ភាគីក្រុមហ៊ុនអាកាសចរជាតិវៀតណាម ។ អគ្គនាយករងត្រូវតែងតាំងដោយក្រុមប្រឹក្សាភិបាល តាមសំណើរបស់ភាគីកម្ពុជា តាមរយៈអគ្គនាយក ។

**មាត្រា ១៥.**

ការចុះ និងអនុវត្តកិច្ចសន្យាដោយក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវគោរពតាមបែបបទ និងនីតិវិធី ដែលកំណត់ដោយលក្ខន្តិកៈរបស់ក្រុមហ៊ុន និងច្បាប់ព្រមទាំងបទបញ្ញត្តិជាធរមាន ។

## ជំពូកទី៣
## ការគ្រប់គ្រងហិរញ្ញវត្ថុ

**មាត្រា ១៦.**

ក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវកាន់កាប់គណនេយ្យរបស់ខ្លួន ឲ្យស្របតាមបទបញ្ញាគណនេយ្យកម្ពុជា និងតាមវិធាននៃគណនេយ្យ ដែលកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

**មាត្រា ១៧.**

ក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" អាចមានគណនីក្នុងធនាគារពាណិជ្ជកម្មផ្សេងៗ ហើយប្រើប្រាស់គណនីនេះសម្រាប់តម្រូវការរបស់ខ្លួន ។

**មាត្រា ១៨.**

ក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវបង់ប្រាក់ចំណូលចូលថវិការដ្ឋទៅតាមការកំណត់ក្នុងកិច្ចព្រមព្រៀងស្តីពីការបង្កើតក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ២០០៩ រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងក្រុមហ៊ុនអាកាសចរជាតិវៀតណាម និងវិសោធនកម្មលើកិច្ចព្រមព្រៀងបង្កើតក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១១ ។

**មាត្រា ១៩.**

ត្រូវបានដាក់ឲ្យនៅអមក្រុមហ៊ុនអាកាសចរជាតិ "កម្ពុជា អង្គរ អ៊ែរ" នូវមន្ត្រីត្រួតពិនិត្យរដ្ឋម្នាក់ ដែលត្រូវតែងតាំងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។ មន្ត្រីត្រួតពិនិត្យរដ្ឋមានសិទ្ធិចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សាភិបាល ហើយអាចផ្តល់យោបល់លើគ្រប់ចំណុចនៃរបៀបវារៈ តែពុំមានសំឡេងអនុម័តឡើយ ។ មន្ត្រីត្រួតពិនិត្យរដ្ឋត្រូវបំពេញបេសកកម្ម ដោយអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ២០ ២១ ២២ ២៣ ២៤ និងមាត្រា ២៥ នៃព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសាធារណៈ ។

## អវសានបញ្ញត្តិ

**មាត្រា ២០**

អនុក្រឹត្យលេខ ១០៦.អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ២១.**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងក្រុមហ៊ុនអាកាសចរណ៍ជាតិ "កម្ពុជា អង្គរ អ៊ែរ" ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០១១

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២១
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ